ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាខេត្តព្រៃវែង

លេខ ០១៦/សខព/១១

## សេចក្តីជូនដំណឹង

## ស្តីពីការប្រមូលពន្ធ-អាករលើសេវាដឹកជញ្ជូន

- បានឃើញច្បាប់សារពើពន្ធ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស-រកម-០២៩៧-០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧
- បានឃើញប្រកាសលេខ ៣៤២ ប្រក.សហវ.ពដ ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីអាករលើផលរបរ។

អភិបាលនៃគណៈអភិបាលខេត្តកត់សម្គាល់ឃើញថា៖ មានម្ចាស់មធ្យោបាយដឹកជញ្ជូនជើងគោក និងជើងទឹកមួយចំនួន ដែលប្រកបមុខរបរដឹកជញ្ជូនអ្នកដំណើរ ឬដឹកទំនិញផ្សេងៗមិនបានបំពេញកាតព្វកិច្ចបង់ពន្ធទៅតាមពេលវេលាកំណត់ឡើយ។

ដើម្បីជំរុញការអនុវត្តន៍ច្បាប់សារពើពន្ធឲ្យមានប្រសិទ្ធិភាព អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង សូមជូនដំណឹង ចំពោះអ្នកជាប់ពន្ធទាំងអស់ជ្រាបថា៖

១- រៀងរាល់ខែ ចាប់ពីថ្ងៃទី ២០ ដល់ថ្ងៃទី ២៥ ត្រូវអញ្ជើញទៅប្រកាសបង់ពន្ធ-អាករ នៅស្នាក់ការពន្ធដារស្រុក ស្ថិតក្នុងស្រុក-ក្រុងដែលខ្លួនរស់នៅ។

២- ករណីល្មើស អភិបាលនៃគណៈអភិបាលស្រុក-ក្រុង ត្រូវចាត់វិធានការសហការរវាងស្នាក់ការពន្ធដារ អធិការដ្ឋាននគរបាល និង កងរាជអាវុធហត្ថស្រុក-ក្រុង ចុះត្រួតពិនិត្យការបង់ពន្ធ-អាករ នៅតាមចំណតរថយន្ត និងកំពង់ចំណត ដើម្បីអនុវត្តការប្រមូលពន្ធ និងផាកពិន័យទៅតាមច្បាប់ជាធរមាន។

ទទួលបាននូវសេចក្តីជូនដំណឹងនេះ អភិបាលនៃគណៈអភិបាលខេត្តមានជំនឿថា គ្រប់អ្នកជាប់ពន្ធទាំងអស់នឹងបំពេញកាតព្វកិច្ចបង់ពន្ធ-អាករ បានទាន់ពេលវេលាកំណត់ជាមិនខានឡើយ។

ព្រៃវែង,ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១១

**អភិបាលនៃគណៈអភិបាលខេត្ត**

**អ៊ុង_សាមី**

**កន្លែងទទួល៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពន្ធដារ
- ក្រុមប្រឹក្សាខេត្តព្រៃវែង
  "គោរពជូនជ្រាប"
- សាលាស្រុក-ក្រុង
- សាខាពន្ធដារខេត្ត
- ស្នងការនគរបាលខេត្ត
- កងរាជអាវុធហត្ថខេត្ត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ